ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៩៩/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តឧត្តរមានជ័យ"

នាព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តឧត្តរមានជ័យ»** ដែលមានវាគ្មិនចូលរួមគឺៈ

- **ឯកឧត្តម ប៉ែន កុសល្យ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តឧត្តរមានជ័យ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យ ដែលរដ្ឋបាលខេត្តឧត្តរមានជ័យ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. ស្ថានភាពទូទៅ

ខេត្តឧត្តរមានជ័យ បែងចែកចេញជា ៥ក្រុង-ស្រុក ២៤ឃុំ-សង្កាត់ និង៣០៨ភូមិ ដោយមានប្រជាពលរដ្ឋរស់នៅសរុប ២៦៤.៩៦៩នាក់ ស្មើនឹង ៦៤.៦៥៦គ្រួសារ។ សេដ្ឋកិច្ចរបស់ខេត្តទាំងមូលពឹងផ្អែកលើវិស័យកសិកម្ម វិស័យរ៉ែ និងវិស័យទេសចរណ៍ ដោយមានទំហំសរុបប្រមាណ ២៥៤.៨ លានដុល្លារអាមេរិក ស្មើនឹង ០,៩% នៃសេដ្ឋកិច្ចជាតិ។ នៅឆ្នាំ២០២១ ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន ៩៤៧ ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ចំនួន ១១.៦៩៧គ្រួសារ ទឹកប្រាក់សរុប ៦៣.២៥០.៨៤០.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ចំនួន ៤.១៤៥នាក់ ចំណាយទឹកប្រាក់សរុប ២.០២១.៩២០.០០០រៀល, ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណាចំនួន ៩០៣គ្រួសារ និងគ្រោះទឹកជំនន់ចំនួន ២.៩០០គ្រួសារ ចំណាយទឹកប្រាក់ ១.៣៦៦.២៧២.០០០រៀល។
- **វិស័យកសិកម្ម៖** ជាខេត្តដែលមានសេដ្ឋកិច្ចផ្តោតជាសំខាន់ ព្រមទាំងមានផ្ទៃដីអំណោយផលខ្លាំងលើវិស័យកសិកម្ម ទូទាំងខេត្តទទួលបានកសិផលកសិកម្ម និងកសិ-ឧស្សាហកម្មមានការកើនឡើងជាលំដាប់ ដែលអាចផ្គត់ផ្គង់ទាំងតម្រូវការក្នុងស្រុក និងនាំចេញទៅក្រៅប្រទេសផងដែរ។ រដ្ឋបាលខេត្ត បាននិងកំពុងលើកកម្ពស់ការងារកសិកម្ម តាមរយៈយន្តការជំរុញការអប់រំបច្ចេកទេសកសិកម្ម និងរៀបចំចងក្រងជាបណ្តុំអាជីវកម្មដំណាំ ក្នុងន័យលើកស្ទួយផលិតភាពដំណាំ ការស្វែងរកទីផ្សារ ធានាបាននូវតម្លៃមួយដែលសមរម្យ មានការឯកភាពគ្នារវាងអ្នកផលិត និងអ្នកប្រមូលទិញ។ ជាមួយគ្នានេះ ប្រព័ន្ធធារាសាស្ត្រខេត្តសំខាន់ៗចំនួន២ គឺទំនប់ស្ទឹងស្រែង១ និងស្ទឹងស្រែង២ ដែលអាចស្តុកទឹកបានប្រមាណជាង ២១១លានម៉ែត្រគូប មានវិសាលភាពអាចគ្របដណ្តប់នូវការផ្គត់ផ្គង់ទូទាំងខេត្ត ព្រមទាំងបានចែកកចាយទៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យផងដែរ។
- **វិស័យអប់រំ៖** ការងារអប់រំ បណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សត្រូវបានយកចិត្តទុកដាក់តាមរយៈការពង្រីកការសាងសង់សាលារៀនជាបន្តបន្ទាប់ ពិសេសនៅតាមទីជនបទ និងតំបន់ដាច់ស្រយាល។ បច្ចុប្បន្ននេះ ទូទាំងខេត្តមានវិទ្យាល័យ ចំនួន៩, អនុវិទ្យាល័យចំនួន៣០, សាលាបឋមសិក្សា ចំនួន២១៩, សាលាបណ្តុះបណ្តាលបច្ចេកទេស ចំនួន២ និងការចូលរួមពីវិស័យឯកជនក្នុងការបណ្តុះបណ្តាលលើផ្នែកភាសា និងជំនាញវិជ្ជាជីវៈផងដែរ។ ជាក់ស្តែងសិក្សា២០២១-២០២២កន្លងទៅ ខេត្តមានបេក្ខជនមកប្រឡងសរុប ១.៦០៤នាក់ (ស្រី ៨៥១នាក់) បេក្ខជនដែលប្រឡងជាប់មានចំនួន ១.២២១នាក់ (ស្រី ៦៨៣នាក់) ស្មើនឹង ៧៦,១២% (ស្រី ៨០,២៦%) ក្នុងនោះមាននិទ្ទេសទទួលបាននិទ្ទេស A ចំនួន ០៦នាក់ (ស្រី ០៥នាក់)។

- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ដោយមានការចូលរួមពីកងកម្លាំងគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទាំងអស់ ទូទាំងខេត្តរក្សាបាននូវសន្តិសុខសណ្តាប់ធ្នាប់ល្អប្រសើរ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ទទួលបានលទ្ធផលល្អ ដោយបានជាប់ចំណាត់ថ្នាក់លេខ១ ចំនួន ២៣ឃុំ-សង្កាត់ និងជ័យលាភីចំណាក់ថ្នាក់លេខ២ មានចំនួន ១ឃុំ ក្នុងចលនាប្រលងប្រណាំងភូមិ-ឃុំមានសុវត្ថិភាពនេះ។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត៖** រដ្ឋបាលខេត្ត បានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍនូវវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដោយបានកែប្រែពីពីផ្លូវដីស ផ្លូវក្រាលគ្រួសក្រហមទៅជាផ្លូវកៅស៊ូ ផ្លូវបេតុង, ការតភ្ជាប់បណ្តាញផ្លូវទៅកាន់បណ្តាឃុំនានា ជាពិសេសធ្វើការតភ្ជាប់តំបន់ដាច់ស្រយាលទៅកាន់តំបន់ទីប្រជុំជន, ការកែលម្អតភ្ជាប់បណ្តាញលូមេក្នុងទីរួមខេត្ត, ការកែលម្អសោភណ្ឌភាពទីប្រជុំជន, ការពង្រីកការតភ្ជាប់បណ្តាញអគ្គិសនី ទឹកស្អាតជូនប្រជាពលរដ្ឋទូទាំងខេត្ត។
- **វិស័យរ៉ែ និងថាមពល៖** ជាខេត្តដែលសម្បូរដោយធនធានរ៉ែ ដែលជាសក្តានុពលលើកស្ទួយសេដ្ឋកិច្ចខេត្តមួយ ដែលធនធានរ៉ែទាំងអស់នោះរួមមាន រ៉ែមាស ត្បូង សំណរ និងរ៉ែថ្មថ្ម។ ដោយឡែក ចំពោះការងារថាមពលអគ្គិសនីវិញ បានផ្គត់ផ្គង់ចំនួន ៩០,៤៧% តាមរយៈក្រុមហ៊ុននិងសេវាករអគ្គិសនីចំនួន ១០។ ជាមួយគ្នានេះ ខេត្តមានរោងចក្រអគ្គិសនីដើរដោយថាមពលធ្យូងថ្មមួយកន្លែងផងដែរស្ថិតក្នុងស្រុកត្រពាំងប្រាសាទ ដោយបានសាងសង់ខ្សែបញ្ជូនអគ្គិសនីពីខេត្តឧត្តរមានជ័យទៅកាន់អនុស្ថានីយ៍ខាងកើតសៀមរាបរួចរាល់ និងគ្រោងដំណើរការក្នុងពេលឆាប់ៗខាងមុខនេះ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តឧត្តរមានជ័យ បានកំណត់ចេញនូវទិសដៅការងារបន្តគឺ បន្តពង្រឹងនូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈ ទាំងសេវាតម្រូវ និងសេវាសំណូមពររបស់ប្រជាពលរដ្ឋ ជាពិសេសទៅលើការងារសុខាភិបាល សំដៅកាត់បន្ថយអត្រាមរណភាពមាតា និងទារក ការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងគ្រប់ប្រភេទ។ ជាមួយគ្នានេះ បន្តជំរុញការលើកកម្ពស់វិស័យកសិកម្ម ដោយខិតខំស្វែងរកទីផ្សារកសិផលកាត់បន្ថយអត្រាភាពក្រីក្រ និងចំណាកស្រុក ព្រមទាំងបន្តកែលម្អ និងអភិវឌ្ឍន៍ការងារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ឱ្យកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀត។

ថ្ងៃអង្គារ ១៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣